**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ញត្តិស្នើសុំដំណោះស្រាយលើបញ្ហាអាទិភាពចំនួន១១ចំនុច ដើម្បីរួមគ្នាការពារសិទ្ធិមូលដ្ឋាន និងទីផ្សារការងាររបស់កម្មករនិយោជិត

ក្នុងឱកាសអបអរទិវាពលកម្មអន្តរជាតិខួបលើកទី១៣៣នេះ យើងខ្ញុំជាកម្មករនិយោជិត សហគមន៍ សមាគម សហជីពនិងអង្គការសង្គមស៊ីវិលដែលកំពុងបំពេញការងារដើម្បីចូលរួមលើកកម្ពស់សិទ្ធិមនុស្ស និង សិទ្ធិការងាររបស់កម្មករនិយោជិត និង ជាពលរដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជា សូមស្នើដល់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេស ក្រសួងកិច្ចការនារី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសុខាភិបាល ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ គណៈកម្មការទប់ស្កាត់ការជួញដូរមនុស្ស ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រុមអ្នកធុរៈកិច្ចបញ្ញាទិញ សូមបន្តខិតខំប្រឹងប្រែងបន្ថែមទៀតក្នុងការឆ្លើយតបចំពោះតម្រូវការចាំបាច់និងបន្ទាន់របស់កម្មករនិយោជិតដើម្បីលុបបំបាត់អំពើហិង្សារាល់ទម្រង់ផ្អែកលើយេនឌ័រ ការកេងចំណេញផ្លូវភេទ ការកេងប្រវ័ញ្ចពលកម្ម និងទាសភាពសម័យទំនើបនៅតាមគ្រឹះស្ថានសហគ្រាស និងសម្រេចបាននូវគោលនយោបាយ និងផែនការយុទ្ធសាស្រ្តជាតិក្នុងការកាត់បន្ថយវិសមភាព យេនឌ័រនិងភាពក្រីក្រនៅកម្ពុជា។

ខាងក្រោមជាតម្រូវការនិងសំណូមពរចំនួន១១(ដប់មួយ) ដែលយើងខ្ញុំស្នើសុំដំណោះស្រាយជាអាទិភាព៖

## តម្រូវការទី១៖ ជម្រុញឲ្យមានការបង្កើតទារកដ្ឋាននៅតាមគ្រឹះស្ថានការងារ និងមត្តេយ្យសហគមន៍នៅគ្រប់ឃុំសង្កាត់

**<u>បញ្ហាដែលបាននឹងកំពុងកើតមានឡើង៖</u>**

- នៅក្នុងរយៈពេលប្រមាណ១៥ឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ក្នុងការបង្កើនលទ្ធភាព គុណភាព និងធានាតម្លៃសមរម្យដើម្បីបង្កើតឲ្យមានមជ្ឈមណ្ឌលទារកដ្ឋាននៅតាមរោងចក្រសហគ្រាស។ ជាក់ស្តែងមាត្រា១៨៦នៃច្បាប់ការងារ បានតម្រូវឱ្យនិយោជកដែលជួលកម្មករស្រ្តីចាប់ពី ១០០នាក់ឡើងបង្កើតទារកដ្ឋាន។ បន្ថែមនេះ នៅឆ្នាំ២០១០រាជរដ្ឋាភិបាលបានបង្កើតគោលនយោបាយជាតិស្តីពីការថែទាំនិងអភិវឌ្ឍន៍កុមារ និងការបង្កើតផែនការសកម្មភាពជាតិស្តីពីការថែទាំនិងអភិវឌ្ឍន៍កុមារឆ្នាំ២០១៤ -២០១៨ និងឆ្នាំ២០១៩- ២០២៣។ ប៉ុន្តែកន្លងមកនេះ ការអនុវត្តច្បាប់និងគោលនយោបាយទាំងនោះនៅមានកម្រិតនៅឡើយ ដោយសារយើងខ្ញុំសង្កេតឃើញថាគ្រឹះស្ថានសហគ្រាសភាគច្រើននៅមិនទាន់បានបង្កើតទារកដ្ឋាននៅឡើយទេ។ ម្យ៉ាងទៀតមណ្ឌលទារកដ្ឋានមួយចំនួនដែលបង្កើតឡើងក៏គ្មានការត្រួតពិនិត្យបទដ្ឋានស្តង់ដារ និងការជម្រុញទឹកចិត្តនិងសម្ភារៈសម្រាប់កុមារគ្រប់គ្រាន់ដែលជាហេតុធ្វើឲ្យក្រុមកម្មករនិយោជិតគ្មានទំនុកចិត្តក្នុងការយកទារកនិងកុមារតូចៗទៅដាក់នៅទីនោះ។
- សេវាថែទាំកុមារនៅតាមមណ្ឌលទារកដ្ឋានឯកជនមានតម្លៃខ្ពស់ ដែលមិនសមស្របជាមួយនិងអាត្រាប្រាក់ចំណូលប្រចាំខែរបស់កម្មករនិយោជិត។ យោងតាមរបាយការណ៍ស្រាវជ្រាវនៅដើមឆ្នាំ២០១៩នេះ កម្រៃសេវានៅតាមមណ្ឌលទារកដ្ឋានឯកជនគិតជាមធ្យមគឺ២៥០(ពីររយហាសិប)ដុល្លាក្នុងមួយខែ ដោយមិនទាន់គិតបញ្ចូល ថ្លៃអាហារសម្លៀកបំពាក់ឬប្រាក់បន្ថែមផ្សេងៗនោះទេ។ អាស្រ័យហេតុនេះស្រ្តីជាកម្មករនិយោជិតតាមរោងចក្រ សហគ្រាស ឬស្រ្តីប្រកបរបរសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលមានកម្រិតជីវភាពមធ្យមឬក្រោមមធ្យមនោះ គ្មានលទ្ធភាពយកកូនតូចៗទៅដាក់នៅមណ្ឌលទារកដ្ឋានឯកជនទេ។
- ដោយសារតែតម្រូវការផ្នែកជីវភាព ស្រ្តីរាប់លានអ្នកបានចាប់ផ្តើមចេញមករកការងារជាកម្មករនិយោជិតនៅតាមរោងចក្រសហគ្រាសឬលក់ដូរតាមដងផ្លូវ ហើយពួកគេជួបនូវបញ្ហាលំបាកយ៉ាងខ្លាំងដោយសារតែគំនាបផ្នែកវប្បធម៌ប្រពៃណីរបស់សង្គមខ្មែរដែលកំណត់ដាក់បន្ទុកឲ្យស្រ្តីបំពេញភារៈកិច្ចមើលថែទាំកូនតូចៗនិង ឪពុកម្តាយចាស់ៗទាំងស្រុង។ កម្មករចំណាកស្រុកជាស្រ្តីភាគច្រើនត្រូវបង្ខំចិត្តយកកូនតូចទៅផ្ញើជាមួយឪពុកម្តាយចាស់ៗនៅឯស្រុកកំណើត ឬត្រូវសម្រេចចិត្តឈប់សម្រាកពីការងារដើម្បីនៅផ្ទះមើលថែកូន ហើយស្រ្តីអ្នកលក់ដូរតាមដងផ្លូវមួយចំនួនត្រូវបង្ខំចិត្តដាក់កូនតាមរទេះរុញ ឬ កណ្តៀតកូនបណ្តើរធ្វើការបណ្តើរ។ ជម្រើសទាំងនេះសុទ្ធតែជាជម្រើសមិនល្អដែលធ្វើឱ្យប៉ះពាល់ដល់សុវត្ថិភាព សុខភាព និងការលូតលាស់របស់កុមារ ព្រមទាំងសុខភាពផ្លូវចិត្តរបស់ស្រ្តីជាម្តាយ។ បន្ថែមលើនេះធ្វើស្រ្តីបាត់បង់ឱកាសក្នុងការអភិវឌ្ឍន៍ ផ្នែកវិជ្ជាជីវៈ និងឬប្រាក់ចំណូល។

## តម្រូវការទី២៖ ជម្រុញឲ្យមានការបង្កើតមជ្ឈមណ្ឌលផ្តល់សេវាគ្រប់ប្រភេទនៅហ្នឹងកន្លែងតែមួយសម្រាប់ស្រ្តីរងគ្រោះអំពើហិង្សាបង្កឡើងដោយដៃគូស្និតស្នាល រួមមានការប្រឹក្សាផ្លូវចិត្ត ការគាំពារផ្លូវច្បាប់ ការព្យាបាលសុខភាពរាងកាយ ការផ្តល់ជម្រកសុវត្ថិភាព និងការការពារសន្តិសុខសុវត្ថិភាពដល់ស្រ្តីរងគ្រោះនិងកូនៗ ប្រព័ន្ធរាយការណ៍តាមទូរស័ព្ទនិងបង្កើតមណ្ឌលអប់រំនិងស្តារនីតិសម្បទាដល់ជនបង្កអំពើហិង្សា។

**<u>បញ្ហាដែលបាននឹងកំពុងកើតមានឡើង៖</u>**

- អាត្រានៃស្ត្រីនិងកុមារីដែលប្រឈមនិងរងគ្រោះដោយសារអំពើហិង្សាគឺស្ថិតក្នុងកម្រិតដែលគួរឲ្យព្រួយបារម្ភណ៍យ៉ាងខ្លាំងជាពិសេសបញ្ហាសុខភាព សុវត្ថិភាពផ្លូវកាយផ្លូវចិត្ត និងស្មារតីរបស់ស្ត្រីនិងកុមារី។ យោងតាមរបាយការណ៍ស្រាវជ្រាវស្ទីអំពីបទពិសោធន៍និងសុខភាពស្ត្រីដែលចេញផ្សាយកាលពីឆ្នាំ២០១៤ "ស្ត្រីនិងកុមារីម្នាក់ក្នុងចំណោមស្ត្រីនិងកុមារីប្រាំនាក់ដែលមានអាយុចាប់ពី១៤ដល់៦៤ឆ្នាំ ធ្លាប់ឬកំពុងរងគ្រោះអំពើហិង្សាមួយឬច្រើនប្រភេទពីដៃគូស្និទស្នាលយ៉ាងហោចណាស់ម្តងក្នុងជីវិតរបស់គាត់គិតត្រឹមកំឡុងពេលនៃការសិក្សានោះ "។ បើយោងតាមទិន្នន័យដែលរាជរដ្ឋាភិបាលបានដាក់បញ្ចូលទៅក្នុងរបាយការណ៍ស៊ីដរដែលបញ្ជូនទៅគណៈកម្មការត្រួតពិនិត្យ ការអនុវត្តន៍អនុសញ្ញាស៊ីដរគិតមកត្រឹមដើមឆ្នាំ២០១៩នេះកម្ពុជាមានមជ្ឈមណ្ឌលសុវត្ថិភាពសម្រាប់ស្ត្រីត្រឹមតែ៦ប៉ុណ្ណោះ។ មណ្ឌលទាំងនោះគឺស្ថិតក្រោមការគ្រប់គ្រងនិងប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិល។ ម្យ៉ាងទៀតរបាយការណ៍ដដែលបានចង្អុលបង្ហាញថាតុលាការបានចេញដីកាការពារសុវត្ថិភាពតែ១៩ករណីប៉ុណ្ណោះ។ នេះមានន័យថានៅពេលដែលស្ត្រីនិងកុមារី និងកម្មករស្ត្រីជួបប្រឈមឬរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ ឬអំពើហិង្សាផ្អែកលើយេនឌ័រនៅកន្លែងការងារគ្មានលទ្ធភាពនៅអោយឆ្ងាយពីជនបង្កហេតុដើម្បីរក្សាការពារអាយុជីវិតរបស់ពួកគេ។ ហើយជនបង្កនៅតែមានឱកាសរំខាន បន្តប្រើហិង្សា និងគំរាមកំហែងដល់ជនរងគ្រោះ។
- យើងសង្កេតឃើញមានការអនុវត្តនីតិវិធីមិនត្រឹមត្រូវឬមិនពេញលេញជាច្រើនបានកើតឡើង។ តួយ៉ាងមានករណីមួយចំនួនធំដែលអាជ្ញាធរមូលដ្ឋានបានអន្តរាគមន៍ឱ្យស្ត្រីយោគយល់ អត់ឱន ផ្តល់ឱកាសឱ្យជនបង្កនិងតម្រូវឱ្យស្ត្រីកែប្រែឥរិយាបថខ្លួនដើម្បីចៀសវាងជម្លោះ។

**តម្រូវការទី៣៖ តម្រូវឱ្យគ្រប់គ្រឹះស្ថានសេវាកំសាន្តបង្កើតនូវគោលនយោបាយទប់ស្កាត់និងប្រឆាំងអំពើបៀតបៀនកេងចំណេញផ្លូវភេទ និងហិង្សាគ្រប់រូបភាពមកលើស្ត្រីកម្មករនិយោជិត ព្រមទាំងពង្រឹងប្រសិទ្ធភាពក្នុងការចុះអធិការកិច្ចការងារដើម្បីធានាសុវត្ថិភាពសិទ្ធិការងារ និងសេចក្តីថ្លៃថ្នូររបស់កម្មករនិយោជិត និងតម្រូវឱ្យគ្រឹះស្ថានសេវាកំសាន្តអនុវត្តការចុះបញ្ជីនៅបេឡាជាតិរបបសន្តិសុខសង្គមសម្រាប់កម្មករនិយោជិត។**

**<u>បញ្ហាដែលបាននឹងកំពុងកើតមានឡើង៖</u>**

- កម្មករនិយោជិតជាស្ត្រីដែលធ្វើការងារផ្នែកសេវាកំសាន្តរួមមាន អ្នកចម្រៀងតាមរង្គសាល អ្នកម៉ាស្សា អ្នកផ្សព្វផ្សាយស្រាបៀរ កាស៊ីណូ និងអ្នករៀបបន្ទប់តាមផ្ទះសំណាក់ឬសណ្ឋាគារប្រឈមនូវការបៀតបៀនរាងកាយ ការចាប់បង្ខំនិងហិង្សាផ្លូវភេទពីសំណាក់អតិថិជន ប៉ុន្តែអ្នកគ្រប់គ្រងឬថៅកែមិនបានយកចិត្តទុកដាក់ដំណោះស្រាយក្រៅពីតម្រូវឱ្យកម្មករទ្រាំទទួលយកនូវអំពើហិង្សានោះ ឬទទួលសំណងជួលជុលផ្លូវចិត្តបន្តិចបន្តួច ហើយមានករណីមួយចំនួនមិនត្រឹមតែមិនដោះស្រាយថែមទាំងបញ្ឈប់ពួកគេពីការងារទៀតផង។
- វប្បធម៌នៃការផ្សះផ្សាក្រៅប្រព័ន្ធតុលាការតាមរយៈការទូទាត់សំណងរដ្ឋប្បវេណីទៅឲ្យជនរងគ្រោះ ដើម្បីបិទសំណុំរឿងផ្នែកព្រហ្មទណ្ឌបានបង្ហាញពីកំសោយនៃការអនុវត្តច្បាប់ និងជម្រុញឱ្យអំពើហិង្សាលើស្ត្រីកើតមានជាបន្តបន្ទាប់។
- អ្នកគ្រប់គ្រងនិងនិយោជកខនៅតាមបណ្តាមជ្ឈមណ្ឌលឬគ្រឹះស្ថានកំសាន្តខារ៉ាអូខេមួយចំនួនបានតម្រូវឲ្យកម្មករនិយោជិតជាស្ត្រីធ្វើតេស្តរកមើលថាមានផ្ទៃពោះ ឬ អត់ និងដាក់លក្ខខណ្ឌឱ្យរំលូតកូនឬត្រូវបណ្តេញចេញពីការងារ។ លក្ខខណ្ឌនេះមិនត្រូវបានប្រកាសជាចំហរជាបទបញ្ជាផ្ទៃក្នុងនោះទេប៉ុន្តែត្រូវបានអនុវត្តដោយសំងាត់។
- ការចុះបញ្ជីបេឡាជាតិរបបសន្តិសុខសង្គមលើគ្រោះថ្នាក់ការងារ ការថែទាំសុខភាព និងប្រាក់សោធននិវត្តន៍ ត្រូវបានកំណត់ដោយច្បាប់ការងារប៉ុន្តែនិយោជកក្នុងវិស័យសេវាកំសាន្តជាច្រើននៅមិនទាន់បានអនុវត្តឡើយ។

**តម្រូវការទី៤៖ កំណែទម្រង់មធ្យោបាយដឹកជញ្ជូនកម្មករនិយោជិតក្នុងវិស័យវាយនភ័ណ្ឌកាត់ដេរនិងដេរស្បែកជើង ដោយបង្កើតគោលនយោបាយស្តីពីការដឹកជញ្ជូនកម្មករនិយោជិត ដោយកំណត់ពីការរៀបចំឡានដឹកជញ្ជូនដែលធានានូវផាសុខភាព សុវត្ថិភាព និងសេចក្តីថ្លៃថ្នូររបស់កម្មករ និងពង្រឹងការអនុវត្តច្បាប់ចរាចរណ៍ឱ្យមានប្រសិទ្ធភាពនិងចាត់វិធានការណ៍ជាបន្ទាន់ចំពោះយានយន្តដែលបើកបរហួសល្បឿនកំណត់និងមិនបានត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តត្រឹមត្រូវ ដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍។**

**<u>បញ្ហាដែលបាននឹងកំពុងកើតមានឡើង៖</u>**

- រថយន្តដឹកជញ្ជូនកម្មករនិយោជិតតែងតែរងគ្រោះថ្នាក់ចរាចរជាញឹកញយក្នុងអំឡុងពេលធ្វើដំណើរ ដោយសារតែរថយន្តដឹកជញ្ជូនភាគច្រើនគឺជាប្រភេទរថយន្តដឹកទំនិញ ខ្វះការត្រួតពិនិត្យគុណភាពលក្ខណៈបច្ចេកទេសឡានឲ្យបានត្រឹមត្រូវនិងអ្នកបើកបរឡានមានពិសារគ្រឿងស្រវឹងនិងបើកលឿនហួសកំណត់។ បន្ថែមលើនេះរថយន្តដឹកជញ្ជូនកម្មករភាគច្រើនគ្មានកន្លែងសម្រាប់អង្គុយឡើយ។
- យោងតាមរបាយការណ៍របបបេឡាសន្តិសុខសង្គមបានឱ្យដឹងថា ករណីគ្រោះថ្នាក់ចរាចរណ៍ក្នុងវិស័យរោងចក្រវាយនភ័ណ្ឌនិងកាត់ដេរស្បែកជើងមានកម្រិតខ្ពស់ជាងគេ (លើសពី៥០%) បើធៀបទៅវិស័យដទៃ។ បើគិតជាភាគរយប្រភេទមធ្យោបាយធ្វើដំណើរដែលរងគ្រោះថ្នាក់ញឹកញាប់ជាងគេគឺម៉ូតូ ដោយឡែកគ្រោះថ្នាក់ដែលបង្កដោយឡានដឹក

កម្មករមាន១៤%ក្នុងឆ្នាំ២០១៥និងមិនដល់១%ផងក្នុងឆ្នាំ២០១៧។ ប៉ុន្តែបើគិតជាតួលេខជាក់ស្តែងគ្រោះថ្នាក់ដោយឡានដឹកកម្មករមានចំនួន៨៨០ករណីក្នុងឆ្នាំ២០១៥ និង៩២ករណីក្នុងឆ្នាំ២០១៧។ ដោយសារឡាននីមួយៗដឹកកម្មករច្រើនលើសលុបប្រសិនគិតទាបបំផុតត្រឹម៣០នាក់ក្នុងមួយឡាន នោះមានន័យថាក្នុងឆ្នាំ២០១៧ មានកម្មករចំនួន២៧៦០នាក់ទៅហើយដែលរងគ្រោះថ្នាក់ដោយសារប្រើប្រាស់ឡានទ្រុង។ របាយការណ៍ក៏បង្ហាញផងដែរថាមូលហេតុចំបងនៃគ្រោះថ្នាក់ចរាចរណ៍គឺកើតឡើងដោយសារការបើកល្បឿនហួសកំណត់។

**តម្រូវការទី៥៖** **កំណត់ប្រាក់ឈ្នួលគោលនិងពង្រឹងយន្តការការពារកម្មករធ្វើការងារតាមផ្ទះ និង បង្កើតទម្រង់កិច្ចសន្យាគម្រូសំដៅការពារសិទ្ធិការងារនិងអត្ថប្រយោជន៍របស់កម្មករ និងជម្រុញនិយោជកឱ្យចុះបញ្ជីរបបបេឡាជាតិសន្តិសុខសង្គមសម្រាប់កម្មករ និងស្នើរាជរដ្ឋាភិបាលផ្តល់សច្ចាប័នអនុសញ្ញាILO189ស្តីពីការការពារកម្មករធ្វើការតាមផ្ទះដើម្បីផ្តល់ការពារសិទ្ធិ និងផលប្រយោជន៍របស់កម្មករក្នុងនិងក្រៅប្រទេស។**

**<u>បញ្ហាដែលបាននឹងកំពុងកើតមានឡើង៖</u>**

- ❖ នៅក្នុងប្រទេសកម្ពុជាមានអ្នកធ្វើការតាមផ្ទះចំនួនប្រមាណ២៥០០០០នាក់ហើយភាគច្រើនជាស្ត្រី។អ្នកធ្វើការតាមផ្ទះនៅមិនទាន់បានទទួលការការពារពីច្បាប់ស្តីពីការងារនៅឡើយទេក្នុងពេលចប្បុន្ននេះ។
- ❖ និយោជក(ម្ចាស់ផ្ទះ)ភាគច្រើនមិនទាន់បានអនុវត្តតាមប្រកាសលេខ២៣៥ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ ២០១៨ របស់ក្រសួងការងារស្តីពីលក្ខខណ្ឌការងារសម្រាប់អ្នកធ្វើការតាមផ្ទះ ជាពិសេសប្រការ១៣ដែលបានចែងអំពីកាតព្វកិច្ចរបស់និយោជកក្នុងការចុះបញ្ជីរបបបេឡាជាតិសន្តិសុខសង្គមលើគ្រោះថ្នាក់ការងារ ការថែទាំសុខភាព និងប្រាក់សោធននិវត្តន៍។ ម្យ៉ាងទៀតប្រកាសលេខ២៣៥នេះនៅមានចំនុចខ្វះខាតមួយចំនួនទៀតដូចជា មិនទាន់បានបញ្ជាក់ពីប្រាក់ខែគោលកិច្ចសន្យាការងាររវាងម្ចាស់ផ្ទះនិងកម្មករ និងមិនបានដាក់បញ្ចូលនូវការឈប់សម្រាកលំហែមាតុភាព និង សម្រាកបុណ្យជាតិផ្សេងៗ។

**តម្រូវការទី៦៖** **ផ្តល់កិច្ចគាំពារសង្គមដល់អ្នកលក់ដូរតាមដងផ្លូវនិងអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធដទៃទៀតតាមរយៈការផ្តល់ប័ណ្ណសមធម៌ឱ្យដល់ពួកគាត់ឡើងវិញ**

**<u>បញ្ហាដែលបាននឹងកំពុងកើតមានឡើង៖</u>**

- ❖ ក្នុងចន្លោះឆ្នាំ២០១៧នៅកំឡុងមុនពេលបោះឆ្នោតជាតិមានការផ្តល់ប័ណ្ណសមធម៌ឲ្យដល់អ្នកលក់ដូរតាមដងផ្លូវនិងអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធមួយចំនួន។ ប័ណ្ណសមធម៌នេះមានសុពលភាពត្រឹមរយៈពេល១ឆ្នាំប៉ុណ្ណោះ នៅពេលដែលប័ណ្ណផុតសុពលភាពប្រើប្រាស់ក្រុមអ្នកលក់ដូរតាមដងផ្លូវនិងអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធមួយចំនួនមិនអាចស្នើសុំប័ណ្ណថ្មីបានទៅដោយសំអាងថាជីវភាពរបស់ពួកគាត់ធូរធារមិនស្របតាមលក្ខខណ្ឌរបស់កម្មវិធីឡើយ។ ការអះអាងនេះមិនឆ្លុះបញ្ចាំងពីស្ថានភាពជីវភាពពិតប្រាកដរបស់អ្នកលក់ដូរតាមដងផ្លូវ ហើយក៏មិនបានយោងទៅលើ លទ្ធផល និងឬភ័ស្តុតាង នៃការស្រាវជ្រាវវិទ្យាសាស្តសង្គមណាមួយឡើយ។
- ❖ យោងតាមសេចក្តីប្រកាសរបស់ក្រសួងការងារស្តីពីស្វ័យនិយោត ក្រសួងមិនបានដាក់បញ្ចូលអ្នកលក់ដូរតាមដងផ្លូវចូលទៅក្នុងអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធនោះទេ ដែលផ្ទុយពីខ្លឹមសារអនុសញ្ញា២០៤ ឆ្នាំ២០១៥របស់ILO។

**តម្រូវការទី៧៖** **ពង្រឹងយន្តការការពារសិទ្ធិពលករចំណាកស្រុកពីការកេងប្រវ័ញ្ចការងារ ការជួញដូរមនុស្ស និង ទាសភាពសម័យទំនើបតាមរយៈ ការធានាឲ្យបាននូវសិទ្ធិកាន់កាប់ឯកសារផ្ទាល់ខ្លួនរបស់ពលករ ការបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យអំពីពលករចំណាកស្រុកដែលរួមមាន ចំនួនពលករ អាស័យដ្ឋានកន្លែងការងារ និងទីកន្លែងស្នាក់ និងបង្កើតជម្រកសុវត្ថិភាពដើម្បីផ្តល់ការឆ្លើយតបបន្ទាន់ដល់ពលករដែលជួបបញ្ហា រួមមានការផ្គត់ផ្គង់អាហារ កន្លែងស្នាក់អាស្រ័យបណ្តោះអាសន្ន និង សេវាប្រឹក្សាយោបល់ និងគួររៀបចំឲ្យ មានកិច្ចជួបប្រជុំជាមួយពលករចំណាកស្រុកមួយឆ្នាំ២ដង។**

**<u>បញ្ហាដែលបាននឹងកំពុងកើតមានឡើង៖</u>**

- ❖ គ្មានប្រព័ន្ធរាយការណ៍ឬទទួលព័ត៌មាន និង ការជួយសង្គ្រោះឬកិច្ចអន្តរាគមន៍នៅពេលដែលពលករចំណាកស្រុករងគ្រោះដោយសារអំពើរំលោភសិទ្ធិមនុស្ស អំពើហិង្សានិងការបៀតបៀនឬនិងរំលោភផ្លូវភេទ។
- ❖ គ្មានយន្តការឬនិងប្រព័ន្ធត្រួតពិនិត្យតាមដានលក្ខខណ្ឌការងារ សុខភាព សុវត្ថិភាព របស់ពលករចំណាកស្រុកឲ្យបានទៀងទាត់ ព្រមទាំងគ្មានការផ្តល់កិច្ចគាំពារសង្គមដល់ពលករបម្រើការងារតាមផ្ទះនៅក្រៅប្រទេស។
- ❖ ស្ត្រីធ្វើការងារតាមផ្ទះត្រូវបានម្ចាស់ផ្ទះដកហូតនូវសិទ្ធិកាន់កាប់ឯកសារស្របច្បាប់ដូចជាលិខិតឆ្លងដែន រួមទាំងសិទ្ធិប្រើប្រាស់ទូរស័ព្ទ។

**តម្រូវការទី៨៖ កំណត់ប្រាក់ឈ្នួលគោលនិងប្រាក់ធានានុគ្រោះសម្រាប់កម្មករនិយោជិតក្នុងវិស័យទេសចរណ៍**

**<u>បញ្ហាដែលបាននឹងកំពុងកើតមានឡើង៖</u>**

- ដោយសារតែគ្មានការកំណត់ប្រាក់ខែគោលរបស់កម្មករនិយោជិតក្នុងវិស័យទេសចរណ៍បណ្ដាលឲ្យនិយោជកជាច្រើនបានបន្ទាប់តម្លៃពលកម្មនិងកំណត់ប្រាក់ខែឬ ប្រាក់ថ្ងៃរបស់កម្មករនិយោជិតតាមទំនើងចិត្ត។ យោងតាមពត៌មានដែលសហជីពទទួលបានពីកម្មករអ្នកសំអាតនិងរៀបចំបន្ទប់នៅតាមសណ្ឋាគារលំដាប់ផ្កាយ៥មួយចំនួនផ្ដល់ប្រាក់ខែគោលដល់កម្មករនិយោជិតប្រមាណត្រឹមតែ ៦៥ ដល់៨៥ដុល្លាតែប៉ុណ្ណោះ។
- កម្មករនិយោជិតនៅក្នុងវិស័យទេសចរណ៍បាត់បង់ផលប្រយោជន៍ដោយសារតែគ្មានគោលការណ៍កំណត់ជាក់លាក់អំពីភាគរយនៃប្រាក់ធានានុគ្រោះនិងគ្មានការផ្ដល់ប្រាក់ធានានុគ្រោះនៅគ្រប់សណ្ឋាគារ។
- និយោជកមួយចំនួនធ្វើការបែងចែកប្រាក់ធានានុគ្រោះតាមតែការយល់ឃើញនិងការសម្រេចរបស់ខ្លួនដោយមិនបានពិភាក្សា ឬ បង្ហាញយន្តការធានាតម្លាភាពនៃការគ្រប់គ្រងនិងបែងចែកប្រាក់ធានានុគ្រោះដល់កម្មករនិយោជិតទេ។ បន្ថែមលើនេះនិយោជកមួយចំនួនបានដាក់វិធានការណ៍កាត់ប្រាក់ធានានុគ្រោះយកទៅទូរទាត់ផលខូចខាតពីការធ្វើឱ្យបែកបាក់សម្ភារៈក្នុងសណ្ឋាគារដែលបង្ករដោយកម្មករនិយោជិត។

**តម្រូវការទី៩៖ កំណត់ប្រាក់ឈ្នួលគោលសម្រាប់កម្មករនិយោជិតក្នុងវិស័យសំណង់និងព្រៃឈើ និងជម្រុញឲ្យនិយោជកក្នុងវិស័យសំណង់នឹងព្រៃឈើចុះបញ្ជីរបបសន្តិសុខសង្គមឱ្យគ្រប់កម្មករទាំងអស់និងដាក់ចេញឆាប់ៗនូវសេចក្ដីប្រកាសស្ដីពីការការពារសុវត្ថិភាពកម្មករពីគ្រោះថ្នាក់ការងារ។**

**<u>បញ្ហាដែលបាននឹងកំពុងកើតមានឡើង៖</u>**

- វិស័យសំណង់ជាវិស័យធំទី២បន្ទាប់ពីវិស័យវាយនភ័ណ្ឌកាត់ដេរនិងដេរស្បែកជើងដែលគិតត្រឹមឆ្នាំ២០១៨ មានកម្មករនិយោជិតចំនួនប្រមាណ២៦០០០០នាក់បំពេញការងារក្នុងវិស័យសំណង់និងព្រៃឈើ ប៉ុន្តែបច្ចុប្បន្ននេះកម្ពុជាមិនទាន់បានកំណត់ប្រាក់ខែគោល ឬប្រាក់ឈ្នួលប្រចាំថ្ងៃអប្បបរិមានៅឡើយ ហើយការអនុវត្តជាក់ស្ដែងនិយោជកផ្ដល់ប្រាក់ឈ្នួលទាបដល់កម្មករនិយោជិត បើប្រៀបធៀបទៅនិងប្រាក់ខែគោលរបស់កម្មករកាត់ដេរ។
- ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ បានផលិតនូវសៀវភៅណែនាំដើម្បីរក្សាសុវត្ថិភាពរបស់កម្មករសំណង់នៅតាមការដ្ឋាន ហើយក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈក៏កំពុងរៀបចំសេចក្ដីប្រកាសដើម្បីតម្រូវឱ្យនិយោជកមានវិធានការណ៍និងផ្ដល់នូវសម្ភារៈការពារសុវត្ថិភាពគ្រប់គ្រាន់ដល់កម្មករ។ ប៉ុន្តែទាំងកម្មករផ្នែកសំណង់ក៏ដូចជាផ្នែកកែច្នៃឈើនៅតែគ្មានសម្ភារៈការពារត្រឹមត្រូវតាមស្ដង់ដារដើម្បីការពារសុវត្ថិភាពរាងកាយនៅឡើយ ហើយជារឿយៗតែងតែរងគ្រោះថ្នាក់ការងារ។
- និយោជកនៅមិនទាន់អនុវត្តន៍បានពេញលេញក្នុងការចុះបញ្ជីរបបសន្តិសុខសង្គមដល់កម្មករសំណង់និងកែច្នៃឈើនៅឡើយ ដូច្នេះនៅពេលដែលកម្មករនិយោជកជួបគ្រោះថ្នាក់ការងារពួកគេមិនទទួលបានសោហ៊ុយព្យាបាល និងការគាំទ្រផ្សេងៗឡើយ។

**តម្រូវការទី១០៖ ពង្រឹងការអនុវត្តច្បាប់និងប្រសិទ្ធភាពនៃការដោះស្រាយជំលោះដីធ្លីដែលកំពុងកើតមានប្រកបដោយយុត្តិធម៌និងតម្លាភាពសំដៅការពារសិទ្ធិនឹងសុវត្ថិភាពដីធ្លីរបស់កសិករខ្នាតតូចការពារស្ថេរភាពទីផ្សាររបស់កសិករ និងដាក់បញ្ចូលកម្មករខ្នាតតូចទៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធដើម្បីទទួលបាននូវអត្ថប្រយោជន៍កិច្ចគាំពារសង្គម។**

**<u>បញ្ហាដែលបាននឹងកំពុងកើតមានឡើង៖</u>**

- កសិករខ្នាតតូចកំពុងតែរងគ្រោះដោយសារជម្លោះដីធ្លីជាមួយក្រុមហ៊ុនសម្បទានសេដ្ឋកិច្ច គម្រោងអភិវឌ្ឍន៍ និងការទន្ទ្រានដីពីអ្នកមានអំណាចមួយចំនួនដែលធ្វើឱ្យកសិករអាក់ខានក្នុងការបង្កបង្កើនផល ធ្លាក់ខ្លួនជំពាក់បំណុលរហូតត្រូវចំណាកស្រុកទៅធ្វើជាពលករ។
- កសិកម្មនៅតែអាស្រ័យផលតាមយថាផលដែលអាចបង្កបង្កើនផលបានតែក្នុងរដូវវស្សាដោយសារតែខ្វះអាងស្ដុកទឹកនិងប្រព័ន្ធធារាស្រ្តគ្រប់គ្រាន់ដែលមិនអាចឲ្យកសិករធ្វើកសិកម្មនៅរដូវប្រាំងបាន និងកង្វះគោលនយោបាយការពារស្ថេរភាពទីផ្សាររបស់កសិករ។
- រាជរដ្ឋាភិបាលកម្ពុជាមិនទាន់ផ្ដល់សច្ចាប័ន និងអនុវត្តន៍តាមកត្តិការសញ្ញាស្ដីពីសិទ្ធិកសិករអន្តរជាតិដែលត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិអនុម័តកាលពីថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០១៨ និងមិនទាន់ទទួលស្គាល់ជាផ្លូវការក្នុងការដាក់បញ្ចូលកសិករខ្នាតតូចជាកម្មករសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដើម្បីទទួលបានការគាំពារដោយផ្លូវច្បាប់ និងទទួលបានអត្ថប្រយោជន៍ពីគោលនយោបាយកិច្ចគាំពារសង្គមនៅឡើយ ។

**តម្រូវការទី១១៖ ដោយបង្កើនការគោរព ការពារ និងលើកស្ទួយសិទ្ធិសហជីពតាមរយៈការធ្វើវិសោធនកម្មច្បាប់សហជីព បញ្ឈប់ការប្រើប្រាស់កិច្ចសន្យាខ្លី និងធ្វើវិសោធនកម្មច្បាប់ស្ដីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងបញ្ឈប់ការប្រើប្រាស់អំពើហិង្សាលើស្ត្រីអ្នកការពារសិទ្ធិមនុស្សដើម្បីរួមគ្នារក្សាស្ថេរភាពទីផ្សារការងារ**

**<u>បញ្ហាដែលបាននឹងកំពុងកើតមានឡើង៖</u>**

- ប្រមាណ ៨០% ទៅ ៨៥% នៃរោងចក្រសហគ្រាសបានប្រើប្រាស់កិច្ចសន្យាមានថេរវេលាខ្លីដើម្បីជួលកម្មករនិយោជិត ដែលធ្វើឲ្យកម្មករនិយោជិតគ្មានសុវត្ថិភាពការងារ បាត់បង់អត្ថប្រយោជន៍និងភ័យខ្លាចក្នុងការចរចារជាមួយនិយោជកពីលក្ខ័ណ្ឌការងាររបស់ខ្លួន។
- ស្ត្រីសកម្មជនសហជីពនិងថ្នាក់ដឹកនាំសហជីព សហព័ន្ធនៅតាមមូលដ្ឋាន និងថ្នាក់ជាតិជាច្រើនរូបក្នុងវិស័យកាត់ដេរ វាយយនភ័ណ្ឌនិងដេរស្បែកជើង ទេសចរនិងសេវាកម្ម។ល។ បាននិងកំពុងតែជាប់បណ្តឹងពីបទបរិហារកេរ្តិ៍ និងបទបំផ្លិចបំផ្លាញលើទ្រព្យសម្បត្តិឯកជន ឬនិង ត្រូវបានផ្តន្ទាទោសដោយប្រព័ន្ធតុលាការ ឬ ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ។ ទន្ទឹមនេះដែរយើងខ្ញុំបានរកឃើញថា៩៨ភាគរយនៃស្ត្រីសកម្មជនដីធ្លីចំនួន៦១២នាក់ ធ្លាប់រងគ្រោះអំពើហិង្សាផ្នែករាយកាយ ផ្លូវចិត្ត និងសេដ្ឋកិច្ច ហើយស្ថានភាពនេះកើតឡើងដោយសារតែអាជ្ញាធរមូលដ្ឋានភាគច្រើនមិនយកចិត្តទុកដាក់បង្កើតឱកាសឲ្យភាគីពាក់ព័ន្ធបានជួបពិភាក្សាស្វែងរកដំណោះស្រាយសមស្របនិងទាន់ពេលវេលាថែមទាំងបានគម្រាមកំហែង និងប្រើអំពើហិង្សា លើរាងកាយ និងស្មារតីទៅលើស្ត្រីសកម្មជនសិទ្ធិមនុស្សក្នុងចេតនារារាំងមិនឲ្យមានការជួបជុំនិងដើរក្បួន នៅទី សាធារណៈដើម្បីទាមទាររកយុត្តិធម៌ ។
- ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលក្នុងទម្រង់បច្ចុប្បន្ននេះមានចរឹកលក្ខណៈរឹតត្បិតដល់សិទ្ធិសេរីភាពក្នុងការចូលរួម និងការបង្កើតអង្គការសមាគមផងដែរ ជាពិសេសជាមាត្រា៦ មាត្រា៨ មាត្រា២៤ និង មាត្រា២៥ ។
- ច្បាប់សហជីពក្នុងទម្រង់បច្ចុប្បន្ននេះមានចរឹកលក្ខណៈរឹតត្បិតសិទ្ធិមូលដ្ឋាននិងសេរីភាពរបស់កម្មករនិយោជិតនិងសហជីពជាក់ស្តែងមាត្រា៥៤ មាត្រា១៤ មាត្រា១៥ និងប្រកាស និងឧបសម្ព័ន្ធបានដាក់បន្ទុកដល់សហជីពក្នុងការចុះបញ្ជីការសហជីព និងសិទ្ធិជាតំណាង។

**Kingdom of Cambodia**
**Nation Religion King**

## Petition Requesting Resolution of 11 Priority Problems to Protect Workers' Fundamental Rights and the Labour Market

On the occasion of 133rd anniversary of International Labour Day, we, as workers, communities, associations, trade unions and civil society organisations working for the promotion of human rights and labour rights, and citizens in the Kingdom of Cambodia, request the Royal Government of Cambodia, in particular the Ministry of Women's Affairs, the Ministry of Labour and Vocational Training, the Ministry of Health, the Ministry of Interior, the Ministry of Justice, the Ministry of Foreign Affairs and International Cooperation, the Commission for the Prevention of Human Trafficking, the Ministry of Land Management, Urban Planning and Construction, the Office of the Council of Ministers, and business groups, to continue efforts to respond to the needs and requirements of workers in order to eliminate all forms of gender-based violence, sexual exploitation, labour exploitation and modern slavery in enterprises, and adopt a policy and National Strategy Plan on achieving gender equality and reducing poverty in Cambodia.

Below are the 11 (eleven) needs and proposals which we request the Royal Government of Cambodia to be implement as a priority:

### 1: Establish nurseries in the workplace, and community-based kindergartens in every commune/sangkat.

**Current problems:**

- In the last fifteen years, the Government has focused on increasing availability and quality of nurseries in factories and ensuring their affordability. Article 186 of the Labour Law is clear in requiring employers with more than one hundred female workers to create a nursery in the workplace. In addition to this, in 2010, the Government formulated a national policy on children's care and development and established a National Action Plan on Children's Care and Development 2014-2018 and 2019-2023. However, the implementation of these laws and policies has been limited; we have observed that many enterprises and establishments have not created nurseries. Moreover, a number of nurseries that have been created do not have controlling standards, or enough materials for children, meaning that workers do not have confidence to leave their children there.
- Childcare services in private nurseries are expensive and disproportionate to workers' monthly wage rates. According to 2019 research, private nurseries cost on average $250 per month, not including costs for food, clothing, or additional expenses. Based on this, female workers in factories and enterprises or the informal economy with lower -or middle- income status are unable to place their children in private nurseries.
- Due to livelihood needs, millions of women look for work in factories and enterprises or sell goods along the street, and they encounter significant problems because of the traditional cultural expectation's Cambodian society places on women to care for children and elderly parents. Many women workers who migrate overseas are forced to leave their children in the care of elderly relatives in their home districts or must decide to stop working to care for their children. A number of women street-vendors are forced to put their children in pushcarts or carry them as they walk. These are not good options and pose a risk to the safety, health and growth of children, as well as mothers' psychological health, but the alternative is that women lose the opportunity to develop their career and/or income.

**2. Establish a one-stop service centre for victims of domestic violence, including the provision of psychological counselling, legal support, physical treatment, a safe shelter and the protection of victims and their children's security; establish a telephone reporting service; and the create an education and rehabilitation centre for perpetrators of violence.**

**Current problems:**

- Rates of violence perpetrated against women and children are worryingly high, in particular incidents involving the physical and mental health and safety of women and children. According to 2014 research about the experiences and health of women, *"one in every five women or girls between the ages of 14 and 64 experienced or were subject to one or more categories of violence from their partner at least once in their life during the period of the study."* According to data included by the Government in its Convention on the Elimination of all forms of Discrimination Against Women (CEDAW) report submitted to the Committee for the Supervision and Implementation of the CEDAW Convention in 2019, Cambodia has only six safe shelters for women. These centres are under the management and operation of civil society organisations. This means that when women and children and women workers are facing or are subject to domestic violence or gender-based violence in the workplace, it is extremely difficult to create distance from the perpetrator to protect themselves and perpetrators still have the opportunity to continue inflicting violence and threats upon the victim.
- We have observed that there is widespread improper or incomplete implementation of official procedure. There have been a number of cases where local authorities have intervened only to encourage women to understand, tolerate, and give another chance to the perpetrator, requiring women to change their attitude to avoid conflict, rather than bringing the perpetrator to justice.

**3. Require all entertainment service establishments to establish policies for the prevention of harassment, sexual exploitation and all forms of violence against women workers; strengthen the capabilities of labour inspection to guarantee the security of the labour rights and dignity of workers; and require entertainment service establishments to register workers with the National Social Security Fund.**

**Current problems:**

- Women workers in the entertainment service sectors, including bar singers, masseuses, beer and casino promoters and guesthouse and hotel cleaners, face physical harassment, exaction and sexual violence from customers. However, management or bosses do not implement solutions, rather, require workers to accept the violence or accept some small compensation. There have been a number of cases where not only is there no resolution, but women victims are terminated from work.
- The culture of reconciliation outside of court processes, through payment of civil compensation to the victim to settle the criminal case, shows the inefficacy of legal implementation and promotes further violence against women.
- Management and employers at a number of karaoke entertainment centres or other establishments have required female workers to take tests to find if they are pregnant or not, demanding abortion or dismissal in the case of pregnancy. This practice is never declared as an internal regulation but is implemented unofficially.
- Registration with the National Social Security Fund for workplace accidents, treatment and pensions is required by the Labour Law. However, many employers in the entertainment service sector have not implemented this.

**4. Reform the methods of transporting workers in the textile, garment and footwear sectors by establishing a policy on transporting workers which determines standards for transport vehicles; guarantee the health, safety and dignity of workers; reduce traffic accidents by strengthening effective implementation of the Traffic Law; and take urgent measures to prevent vehicles from travelling over the speed limit or not conforming to controlling vehicle technical specifications.**

**Current problems:**

- Vehicles transporting workers are regularly involved in traffic accidents during journeys, either because the trucks used for transportation lack proper vehicle quality control or because drivers are intoxicated or exceed the speed limit. Additionally, many of the vehicles transporting workers do not have room for passengers to sit down; instead workers stand in open trucks.
- According to a National Social Security Fund report, traffic accidents in the textile, garment and footwear sectors occur 50% more frequently than in other sectors. The most common type of accident by percentage is motorbikes, whilst traffic accidents caused by trucks transporting workers accounted for 14% of accidents in 2015 and less than 1% in 2017. However, the number of accidents involving trucks transporting workers was 880 in 2015 and 92 in 2017. Because each truck is transporting many workers, with 30 people at the very least per vehicle, this means that in 2017 2760 workers were victims of traffic accidents. The report also showed that the primary reason for traffic accidents was speeding.

**5. Set a minimum wage and strengthen protection mechanisms for domestic workers, including by creating a model contract for protecting the labour rights and benefits of workers; urge employers of domestic workers to register domestic workers with the National Social Security Fund; and ratify ILO Convention No. 189 on the Protection of Domestic Workers to protect the rights and benefits of domestic workers inside and outside Cambodia.**

**Current problems:**

- In Cambodia there are approximately 250,000 domestic workers and many are women. Domestic workers still do not receive protection under the Labour Law.
- Many employers (house owners) have not implemented Prakas No. 235, dated 29 May 2018 from the Ministry of Labour and Vocational Training, on Working Conditions for Domestic Workers, especially Article 13 which states the duties of employers in registering domestic workers with the National Social Security Fund for workplace accidents, healthcare and pensions.
- Prakas No. 235 on Working Conditions for Domestic Workers has a number of shortcomings, including lack of confirmation about minimum wage, employment contracts between the house owner and the worker, maternity leave and national holiday leave.

**6. Provide social protection for street vendors and workers in the informal economy by providing them with valid equity cards.**

**Current problems:**

- In 2017, during the period before the national elections, a number of street vendors and workers in the informal economy were provided with equity cards. These equity cards had a validity of one year and when they expired, the street vendors-sellers and workers in the informal economy could not request new cards, the reason being that their living standards did not fulfil the conditions of the program. This reason did not reflect the reality of street' vendors' lives and does not refer to the results and/or evidence of any investigation.

- According to the Prakas on Self-Employed Persons from the Ministry of Labour, the Ministry does not countstreet vendors as members of the informal economy, in contravention of the contents of ILO Convention No. 204.

**7. Strengthen protection mechanisms for migrant workers from labour exploitation, human trafficking and slavery; modernise through ensuring workers' rights to hold personal documents; establish data management systems to document migrant workers, including the number of workers, addresses of workplaces and residences; establish a safety shelter to provide immediate care to workers who experience problems, including provision of food, temporary accommodation and counselling services; organise a meeting with migrant workers every year.**

**Current problems:**

- There is no system for reporting or receiving information from migrant workers, let alone rescue or intervention when migrant workers suffer human rights violations, violence, harassment or sexual abuse.
- There are no mechanisms and/or systems for supervising the working conditions or health and safety of migrant workers, and there is no provision of social protection to domestic workers overseas.
- House owners deprive women domestic migrant workers of their right under the law to hold identity documents such as passports, as well as their right to communicate with people over the phone.

**8. Set a minimum wage and gratuities for workers in the tourism sector.**

**Current problems:**

- Because there is no set monthly minimum wage for workers in the tourism sector, many employers provide low pay and set arbitrary monthly or daily wages. According to information received by trade unions from cleaners in a number of five-star hotels, a number of employers provide a basic wage of approximately $65 to $85 per month.
- Workers in the tourism sector have lost benefits because of the lack of a specific policy on service charges, with these allowances not provided in every hotel.
- A number of employers divide gratuities based on their own understanding and decisions without a transparent mechanism of managing and dividing gratuities to employees. In addition to this, a number of employers have imposed a measure of deducting tips as compensation for damage to hotel property caused by the worker.

**9. Set a minimum wage for workers in the construction and forestry sectors; urge employers in those sectors to register all workers with the National Social Security Fund; and promptly issue a Prakas on the protection of workers from workplace accidents.**

**Current problems:**

- The construction sector is the second largest in Cambodia after the textile, garment and footwear sectors. In 2018, there were approximately 260,000 workers in the construction and forestry sectors. However, Cambodia has still not yet set a minimum monthly or daily wage for this sector and the effect is that employers provide low wages to workers in comparison to garment workers.
- The Ministry of Land Management, Urban Planning and Construction has produced a manual to guide employers in keeping construction workers safe at work and the Ministry of Labour and Vocational Training is preparing a Prakas to require employers to take measures to provide sufficient protective safety materials to workers. However, both construction and building material workers remain without proper protective safety equipment to protect their physical safety and are often victims of workplace accidents.

- Employers have still not fully implemented registration of construction and woodworkers with the National Social Security Fund (NSSF). Therefore, when workers suffer workplace accidents, they do not receive treatment costs and other support.

**10. Strengthen implementation of the law and the efficiency of just and transparent resolutions for current land disputes to protect the land rights and security of small farmers; protect the stability of farmers' markets; and include small farmers in the informal economy to receive social protection benefits.**

**Current problems:**

- Small farmers are currently suffering the effects of land disputes with companies that have been granted economic land concessions, development projects and land grabbing from a number of powerful people, causing farmers to fail in cultivation of crops, fall into debt and migrate overseas for work.
- Agriculture is still dependent on the fact that crops can only be harvested in the rainy season due to a lack of sufficient reservoirs and irrigation systems, preventing farmers from working in the dry season. Additionally, there is a lack of policy to protect the stability of farmers' markets.
- The Royal Government of Cambodia has still not ratified and implemented the United Nations Declaration on the Rights of Peasants and Other People Working in Rural Areas adopted by the United Nations General Assembly on 18 December 2018 and has not officially recognised the inclusion of small farmers in the informal economy to receive legal support and benefits from social protection policies.

**11. Increase the respect, protection and promotion of trade union rights through amendments to the Law on Trade Unions; end the use of short-term contracts; amend the Law on Associations and Non-Governmental Organisations; and end violence against women and human rights defenders to consolidate labour market stability.**

**Current problems:**

- Approximately 80% to 85% of factories engage workers on short-term contracts, which means workers lack job security, lose benefits, and are fearful of negotiating working conditions with their employer.
- Local, federation and national female trade union activists and leaders in the garment, textile and footwear, tourism, service, etc., sectors have had complaints of defamation and criminal destruction of private property taken out against them, and/or have been convicted by the judicial system or are still under investigation by the court. 98% of 692 land activists have been subject to physical, mental and economic violence and this situation occurs because many local authorities do not focus on creating opportunities for relevant parties to meet to discuss and find appropriate and timely solutions to land disputes, even threatening and using violence against the physical welfare and dignity of women human rights activists with the intention of blocking public marches to demand justice.
- The Law on Associations and Non-Governmental Organisations restricts the fundamental freedoms of workers, including the right to establish an organisation or association, particularly under Article 6, Article 8, Article 24 and Article 25.
- The Law on Trade Unions in its current form restricts the fundamental rights and freedoms of workers and trade unions, imposing mandatory and burdensome registration requirements and broad grounds for the denial of registration, which fail to comply with international standards on Freedom of Association, particularly under Article 14, Article 15, Article 17 and Article 54 and the Prakas and Annexes imposed on unions regarding registering trade unions and representation rights.